


## អំពី Explore

Explore គឺជាបណ្ដាញអ្នកស្រាវជ្រាវ និងអ្នកអនុវត្តការងារ ដែលចង់ពង្រីក និងប្រើប្រាស់ចំណេះដឹងរបស់ពួកគេ ពីអភិបាលកិច្ចក្នុងតំបន់ទេសភាពព្រៃឈើ នៅអាស៊ីអាគ្នេយ៍។ បណ្ដាញនេះប្រើប្រាស់អភិក្រម ពហុវិស័យ ការចូលរួម បរិយាប័ន្នពីពហុភាគីអ្នកពាក់ព័ន្ធ ដើម្បីរួមចំណែកសម្រេចឱ្យបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាព កិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្ដីពីការប្រែប្រួលអាកាសធាតុ និងការប្ដេជ្ញាចិត្តជាតិ និងអន្តរជាតិដទៃទៀត។ បណ្ដាញនេះ សង្កត់ធ្ងន់លើសមភាពយេនឌ័រ បរិយាប័ន្នសង្គម កិច្ចសហការឆ្លងដែន និង ការដោះស្រាយបញ្ហា។ សមាជិក ក្រុមប្រឹក្សាភិបាលរបស់ Explore ជាង ៥០% គឺជាស្ត្រី ហើយក៏នឹងស្វែងរកចំនួនអ្នកស្រាវជ្រាវជាស្ត្រីឲ្យស្មើនឹងបុរសផងដែរ។

បណ្ដាញនេះចាប់ផ្ដើម នៅខែតុលា ឆ្នាំ២០២០ និងទទួលបានមូលនិធិគាំទ្រពីទីភ្នាក់ងារស៊ុយអែតសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិ (Sida)។ បណ្ដាញនេះដឹកនាំដោយអង្គការរីខូហ្វ (RECOFTC) ក្រោមភាពជាដៃគូជាមួយមជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវព្រៃឈើអន្តរជាតិ (CIFOR) ព្រមទាំងសហការជាមួយសាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ រដ្ឋាភិបាល អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងវិស័យឯកជន ក្នុងតំបន់អាស៊ីអាគ្នេយ៍។

Explore សូមស្វាគមន៍ការចូលរួមពីសាកលវិទ្យាល័យ អ្នកស្រាវជ្រាវ អ្នកបង្កើតគោលនយោបាយ អ្នកអនុវត្តការងារ ក្រុមហ៊ុន ម្ចាស់ជំនួយ គ្រឹះស្ថានអភិវឌ្ឍ និង តំណាងសហគមន៍ព្រៃឈើ ។

## សេចក្ដីប្រកាសទទួលឯកសារទស្សនទាន តាមរយៈយន្តការហិរញ្ញប្បទានរបស់ Explore

នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ Explore បានផ្សព្វផ្សាយ ជាលើកដំបូងពីការជ្រើសរើសឯកសារទស្សនទានសម្រាប់ការស្រាវជ្រាវ អំពីអភិបាលកិច្ចតំបន់ទេសភាពព្រៃឈើ តាមរយៈកិច្ចប្រជុំតាមវីដេអូ (videoconference) ដែលរៀបចំឡើងដោយវេទិកាតំបន់ទេសភាពសកល (Global Landscapes Forum)។ អ្នកចូលរួមបានដឹងពីដំណើរការ កាលវិភាគ និងនីតិវិធីវាយតម្លៃ លើឯកសារទស្សនទានដែលបានដាក់មកចូលរួម។

សម្រាប់ឯកសារដែលទទួលបានការជ្រើសរើស Explore នឹងផ្ដល់មូលនិធិ ដើម្បីរៀបចំគម្រោងសំណើរស្រាវជ្រាវ ការបណ្ដុះបណ្ដាល ការគាំទ្រ និងធ្វើការណែនាំ។

កាលបរិច្ឆេទផុតកំណត់សម្រាប់ការដាក់ពាក្យគឺត្រឹម **ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១**។

សម្រាប់ព័ត៌មានបន្ថែមអំពីការផ្សព្វផ្សាយ សូមចុចត្រង់នេះ៖ recoftc.org/projects/explore/explore-call-concept-notes-application

## ក្រុមអ្នកអនុវត្ត

Explore មានសមាជិកពីអ្នកអនុវត្ត ដែលប្ដេជ្ញាចិត្តចំពោះអភិបាលកិច្ចសម្រាប់តំបន់ទេសភាពព្រៃឈើ រៀបចំដោយវេទិកាតំបន់ទេសភាពសកល (GLF) និង សម្របសម្រួលដោយអង្គការរីខូហ្វ (RECOFTC)។ GLF គឺជាវេទិកាចំណេះដឹងធំបំផុតក្នុងពិភពលោក ស្ដីពីតំបន់ទេសភាពប្រកបដោយចីរភាព។ វេទិកានេះផ្ដល់ឱកាសឲ្យសមាជិករបស់ Explore ភ្ជាប់ទំនាក់ទំនង រៀនសូត្រ កំណត់ប្រភពមូលនិធិ និង បន្តការងាររបស់ពួកគេឱ្យកាន់តែប្រសើរ។

សូមចុចត្រង់នេះដើម្បីចូលរួមជាមួយនឹងក្រុមអ្នកអនុវត្ត៖ https://glfx.globallandscapesforum.org/topics/25431

## អត្ថប្រយោជន៍សម្រាប់សមាជិក

**សាកលវិទ្យាល័យ និងអ្នកស្រាវជ្រាវ**
កសាងសមត្ថភាពក្នុងការរៀបចំ អនុវត្ត និង បង្ហាញពីការស្រាវជ្រាវរបស់ខ្លួន ដើម្បីទទួលបានមូលនិធិគាំទ្រ និង ការណែនាំ ព្រមទាំងអាចចូលរួមធ្វើការជាមួយអ្នកស្រាវជ្រាវផ្សេងទៀត សាស្ត្រាចារ្យ សហគមន៍ព្រៃឈើ អ្នករៀបចំគោលនយោបាយ ស្ថាប័ន និង ក្រុមហ៊ុននានា។

**អ្នករៀបចំគោលនយោបាយ**
ជួយផ្តល់ការណែនាំចំពោះសំនួរស្រាវជ្រាវ និងអាចយកលទ្ធផលពីការស្រាវជ្រាវ ជួយដល់ការកែលម្អគោលនយោបាយ និងក្របខ័ណ្ឌស្ថាប័ន សម្រាប់ការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និងចីរភាព។

**អ្នកធ្វើការងារលើការអភិវឌ្ឍប្រកបដោយចីរភាព ការកាត់បន្ថយភាពក្រីក្រ បរិយាប័ន្នយេនឌ័រ និងបរិយាប័ន្នសង្គម**
អាចបង្កើនចំណេះដឹង ជំនាញបច្ចេកទេស និង ឪកាសជួបជាមួយអ្នករៀបចំគោលនយោបាយ ការបង្កើនសមត្ថភាព ដើម្បីបម្រើការងារជូនសហគមន៍មូលដ្ឋាន និង ក្រុមដែលមិនសូវ ទទួលបានការយកចិត្តទុកដាក់។

**អ្នកវិនិយោគ និង ក្រុមហ៊ុន**
ចាប់ដៃគូជាមួយសហគមន៍មូលដ្ឋាន កាត់បន្ថយហានិភ័យ ធានាបាននូវសង្វាក់ផ្គត់ផ្គង់ កំណត់ទិសដៅសម្រាប់សំនួរស្រាវជ្រាវបានលឿន សហការផ្តល់មូលនិធិគាំទ្រដល់ការស្រាវជ្រាវ ក៏ដូចជារួមចំណែកដល់ការសម្រេចបាននូវគោលដៅ និង កិច្ចព្រមព្រៀងអន្តរជាតិលើផ្នែកសេដ្ឋកិច្ច បរិស្ថាន និងសង្គម។

**អ្នកតំណាងសហគមន៍មូលដ្ឋាន**
ភ្ជាប់ទំនាក់ទំនងជាមួយបុគ្គលនានា និង ស្ថាប័នដែលអាចជួយដល់ការធានាបាននូវសិទ្ធិដីធ្លី និងព្រៃឈើ ចូលរួមក្នុងដំណើរការការធ្វើសេចក្តីសម្រេចចិត្ត ទទួលបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និង សមភាពយេនឌ័រ ព្រមទាំងការពារតំបន់ទេសភាពព្រៃឈើ។

**ម្ចាស់ជំនួយ**
កំណត់បាននូវភាពខ្វះចន្លោះក្នុងការស្រាវជ្រាវ និងការអភិវឌ្ឍ កែលម្អការកំណត់ចុះគោលដៅ ដែលជះឥទ្ធិពលលើគោលនយោបាយស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព និង កំណត់រកឱកាស ដែលអាចបានផលប្រយោជន៍ច្រើនសម្រាប់ការបណ្តាក់ទុន។

**វិទ្យាស្ថានអភិវឌ្ឍ**
រកឃើញឱកាសសម្រាប់ការស្រាវជ្រាវ ភាពជាដៃគូ និង ការវិនិយោគ ព្រមទាំងចូលរួមជាមួយអ្នកស្រាវជ្រាវ ដើម្បីអាចដោះស្រាយបញ្ហា ដែលផ្នែកស្រាវជ្រាវប្រឈមសម្រាប់ការអភិវឌ្ឍ (R4D)។

## ប្រធានបទ

- តួនាទីរបស់គោលនយោបាយ និង ស្ថាប័ននានា សម្រាប់ការអភិវឌ្ឍតំបន់ទេសភាពព្រៃឈើដោយចីរភាព
- ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើសហគមន៍មូលដ្ឋាន និង យន្តការឆ្លើយតប
- តួនាទីរបស់ស្ត្រី និង ក្រុមដែលមិនសូវទទួលបានការយកចិត្តទុកដាក់ដទៃទៀត ក្នុងការគ្រប់គ្រងធនធានធម្មជាតិ
- បម្រែបម្រួលធនធាន ព្រៃឈើ និង ផលប៉ះពាល់ទៅលើជីវភាពរស់នៅក្នុងមូលដ្ឋាន និង ភាពក្រីក្រ
- ការថ្លឹងថ្លែងរវាងការអភិវឌ្ឍសេដ្ឋកិច្ច ការអភិរក្សបរិស្ថាន និង សិទ្ធិមនុស្ស នៅពេលរៀបចំផែនការប្រើប្រាស់ដី
- ការពង្រីកវេទិកាអភិបាលកិច្ចព្រៃឈើប្រកបដោយប្រសិទ្ធភាព
- ការធ្វើវិមជ្ឈការការងារគ្រប់គ្រងធនធានធម្មជាតិ
- ការផ្សាភ្ជាប់ទំនាក់ទំនងរវាងព្រៃឈើ ស្បៀងអាហារ និង ទឹក
- ការកាត់បន្ថយហានិភ័យ ក្នុងការវិនិយោគទៅលើដី និង ព្រៃឈើ
- អភិបាលកិច្ចព្រៃឈើ និង គោលដៅអភិវឌ្ឍប្រកបដោយចីរភាព
- អភិបាលកិច្ចព្រៃឈើ ការឆ្លើយតបទៅនឹងជំងឺកូវីដ១៩ និងភាពធន់
- ការពឹងផ្អែកគ្នា និង ទំនាក់ទំនងរវាងសហគមន៍មូលដ្ឋាន និង ធនធានធម្មជាតិក្នុងតំបន់ទេសភាពព្រៃឈើ
- ការគាំទ្រដល់អ្នកស្រាវជ្រាវដែល ផ្តោតលើអភិបាលកិច្ចតំបន់ទេសភាពព្រៃឈើ

## សម្រាប់ព័ត៌មានបន្ថែម

www.recoftc.org/projects/explore
explore.secretariat@recoftc.org
https://glfx.globallandscapesforum.org/topics/25431